00153007

A421/I



**Declassified to Public**
**06 September 2012**

## ការិយាល័យសហចៅក្រមស៊ើបអង្កេត

## អនុស្សរណៈអន្តរការិយាល័យ

ផ្ញើជូន: ប្រធានមន្ទីរឃុំឃាំង អ.វ.ត.ក.

កាលបរិច្ឆេទ: ២០/១១/២០០៧

តាមរយៈ: មន្ត្រីទំនាក់ទំនងមន្ទីរឃុំឃាំង អ.វ.ត.ក.

ពី: ចៅក្រម ម៉ាសែល ឡឺម៉ុង

ចៅក្រម យូ ប៊ុនឡេង

កម្មវត្ថុ: ការឆ្លើយតបទៅនឹងសំណើរបស់មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧

សូមលោកធ្វើការជូនដំណឹងទៅមេធាវីរបស់ជនជាប់ឃុំ កាំង ហ្កេកអ៊ាវ ហៅ ឌុច អំពីការឆ្លើយតបដូចខាងក្រោម ទាក់ទងទៅនឹងសំណើដែលគាត់បានធ្វើកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ កន្លងទៅនេះ:

ចាប់ពីពេលនេះតទៅ និង រហូតមានការជូនដំណឹងថ្មី យើងអនុញ្ញាតឲ្យ កូន និងចៅរបស់លោក កាំង ហ្កេកអ៊ាវ ដែលមានអាយុចាប់ពីដប់ប្រាំបីឆ្នាំឡើងទៅ រួមទាំងប្តីឬប្រពន្ធរបស់កូននិងចៅរបស់លោក កាំង ហ្កេកអ៊ាវ និង បងប្អូនបង្កើតរបស់លោក កាំង ហ្កេកអ៊ាវ អាចមកជួបសួរសុខទុក្ខជនត្រូវចោទ កាំង ហ្កេកអ៊ាវ បាន ។ អ្នកផ្សេងក្រៅពីនេះ មិនត្រូវបានអនុញ្ញាតឲ្យចូលជួបសួរសុខទុក្ខទេ។

ចំនួន ការរៀបចំ កាលវិភាគ នៃការមកសួរសុខទុក្ខបែបនេះ នឹងត្រូវកំណត់អនុលោមតាមបទប្បញ្ញត្តិនៅក្នុងឧបសម្ព័ន្ធ ក នៅខណៈដែលរង់ចាំការអនុម័តនូវវិធានផ្លូវការនៃមន្ទីរឃុំឃាំង។

ORIGINAL DOCUMENT
RECEIVED ON 21/11/2007
AT 9:10' BY
NUP SOTHUNVICHET
ACTING CASE FILE OFFICER

**បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម**
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 21 ខែ(Month/Mois) Nov.
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier NUP SOTHUN VICHET

A42/I

# ឧបសម្ព័ន្ធ ក

១. ប្រធានមន្ទីរឃុំឃាំង ត្រូវរក្សាទុកលិខិតអនុញ្ញាតឲ្យចូលក្នុងសំណុំរឿងរបស់ជនជាប់ឃុំ។ កាលណាមានការទទួលបានការអនុញ្ញាតម្តងរួចហើយ ភ្ញៀវនោះអាចចូលសួរសុខទុក្ខម្តងទៀតបានក្នុងអំឡុងម៉ោងធ្វើការ ដោយគ្រាន់តែសុំការអនុញ្ញាតជាមុនពីប្រធានមន្ទីរឃុំឃាំងប៉ុណ្ណោះ ហើយភ្ញៀវនោះលែងមានសិទ្ធិចេញចូលតទៅទៀត លើកលែងតែនិងលុះត្រាតែប្រធានមន្ទីរឃុំឃាំងបានទទួលលិខិតជូនដំណឹងពីសហចៅក្រមស៊ើបអង្កេត តាមរយៈប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល។ នៅពេលចេញចូលសួរសុខទុក្ខ ភ្ញៀវនឹងត្រូវតែមានកាន់អត្តសញ្ញាណប័ណ្ណ មានបិតរូបថតនិងមានសុពលភាពមកជាមួយផង។

២. អនីតិជនអាយុក្រោម១៨ឆ្នាំ មិនត្រូវបានអនុញ្ញាតឲ្យចូលសួរសុខទុក្ខជាមួយជនជាប់ឃុំទេ លើកលែងតែមាននីតិជនជាអ្នកនាំមកជាមួយ។

៣. ប្រធានមន្ទីរឃុំឃាំងត្រូវ៖

- អនុញ្ញាតឲ្យមានការចូលសួរសុខទុក្ខនៅថ្ងៃធ្វើការពីម៉ោង ៨០:៣0 ដល់ ១១០:៣0ព្រឹក និង ពីម៉ោង២០:00 ដល់ម៉ោង ៤០:00ល្ងាច ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រ។
- កំណត់រយៈពេលនិងប្រភេទនៃការចូលសួរសុខទុក្ខរបស់ក្រុមគ្រួសារនិងមិត្តភ័ក្តិ។ ជាទូទៅ ការសួរសុខទុក្ខនិមួយៗមិនត្រូវមានរយៈពេលលើសពី ៤៥នាទីឡើយ លើកលែងតែប្រធានមន្ទីរឃុំឃាំងបានអនុញ្ញាតផ្សេងពីនេះ។
- ចាត់តាំងអ្នកយាមក្នុងមន្ទីរឃុំឃាំងដើម្បីត្រួតពិនិត្យការចូលសួរសុខទុក្ខ។
- កំណត់ចំនួននីតិជនដែលអាចចូលសួរសុខទុក្ខជនត្រូវឃុំក្នុងពេលណាមួយ។
- ធានាថាមានតែទំនាក់ទំនងខាងរាងកាយនិងអាកប្បកិរិយាដែលសង្គមទទួលស្គាល់ទេ ដែលត្រូវបានអនុញ្ញាតឲ្យមានក្នុងពេលសួរសុខទុក្ខ។
- កំណត់នូវវត្ថុអ្វីខ្លះដែលភ្ញៀវអាចហុចទៅឲ្យជនជាប់ឃុំបាន និងប្រសិនបើមានការចាំបាច់ ធានាឲ្យមានការឆែកឆេរនិងកត់ត្រាវត្ថុនោះចូលក្នុងទម្រង់បញ្ជីទ្រព្យរបស់ជនជាប់ឃុំ។
- កំណត់កាលៈទេសៈសម្រាប់អនុញ្ញាតឲ្យចូលសួរសុខទុក្ខ ដោយមូលហេតុអាណិតអាសូរ ដោយសារភ្ញៀវបានធ្វើដំណើរមកពីកន្លែងឆ្ងាយ ឬកាលណាមានវិបត្តិក្នុងគ្រួសារជនជាប់ឃុំ ដូចជាមរណភាព ឬការគ្រោះថ្នាក់អ្វីមួយ។

00153009

A42/I

៤. ប្រធានមន្ទីរឃុំឃាំងអាចបដិសេធការចូលសួរសុខទុក្ខរបស់ជនដែលស្រវឹងសុរា ឬមានការសង្ស័យថាស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬជនដែលស្ថិតក្រោមឥទ្ធិពលស្រវឹងពីសារធាតុដែលមិនស្គាល់ ឬជនដែលមានអាកប្បកិរិយាបំពាន ឬបង្ហាញនូវអាកប្បកិរិយាដែលមិនអាចគ្រប់គ្រងបាន។

៥. ប្រធានមន្ទីរឃុំឃាំងអាចហាមឃាត់មិនឱ្យភ្ញៀវចូលសួរសុខទុក្ខជនជាប់ឃុំ ប្រសិនបើប្រធានមន្ទីរឃុំឃាំងយល់ឃើញថាភ្ញៀវនោះអាចបង្កការគំរាមកំហែងដល់សន្តិសុខនិងសណ្តាប់ធ្នាប់ល្អរបស់មន្ទីរឃុំឃាំង។ ប្រធានមន្ទីរឃុំឃាំងអាចកំណត់រយៈពេលនៃការហាមឃាត់ភ្ញៀវមិនឱ្យចូលសួរសុខទុក្ខជនត្រូវឃុំ។ ប្រសិនបើភ្ញៀវត្រូវបានហាមឃាត់មិនឱ្យចូលសួរសុខទុក្ខជនជាប់ឃុំ ប្រធានមន្ទីរឃុំឃាំងត្រូវតែដាក់របាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត ប្រធាន និងអនុប្រធាន អ.វ.ត.ក. ព្រមទាំងប្រធានអគ្គនាយកដ្ឋានពន្ធនាគារ ដោយបញ្ជាក់ពីឈ្មោះភ្ញៀវនិងជនជាប់ឃុំ អំពីមូលហេតុនិងរយៈពេលនៃការហាមឃាត់។ ត្រូវរក្សាទុកកំណត់ត្រានៃព័ត៌មាន នេះនៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន។

៦. ត្រូវកត់ត្រាពីវត្ថុ ឬប្រាក់កាសដែលភ្ញៀវនាំយកមកឱ្យជនជាប់ឃុំ។

៧. ប្រធានមន្ទីរឃុំឃាំងត្រូវកំណត់កាលៈទេសៈ ដែលអាចអនុញ្ញាតឱ្យមានការសួរសុខទុក្ខនៅពេលជនត្រូវឃុំត្រូវបានអនុញ្ញាតឱ្យចូលមន្ទីរពេទ្យ។ ការអនុញ្ញាតឱ្យចូលសួរសុខទុក្ខជនជាប់ឃុំនៅក្នុងមន្ទីរពេទ្យ ត្រូវតែធ្វើឡើងក្នុងម៉ោងពិនិត្យសុខភាពធម្មតារបស់មន្ទីរពេទ្យ និងត្រូវកត់ត្រាដូចខាងលើ។

៨. ទោះបីជាក្នុងករណីណាក្តី ប្រធានមន្ទីរឃុំឃាំង និងអ្នកយាមមន្ទីរឃុំឃាំង មិនត្រូវយកប្រាក់ ឬអំណោយអ្វីមួយពីភ្ញៀវសំរាប់ការផ្តល់សិទ្ធិឱ្យចូលសួរសុខទុក្ខជនជាប់ឃុំឡើយ។

៩. គ្រប់ពេលនៃការចូលសួរសុខទុក្ខនិមួយៗ ត្រូវគោរពតាមនីតិវិធីដូចខាងក្រោមនេះ៖

- ប្រធានមន្ទីរឃុំឃាំងត្រូវជូនដំណឹងទៅប្រធានផ្នែកសន្តិសុខនិងសុវត្ថិភាព អំពីការចូលសួរសុខទុក្ខឱ្យបាន ២៤ម៉ោងមុន។
- ភ្ញៀវទាំងឡាយអាចចូលទៅកាន់មន្ទីរឃុំឃាំងបណ្តោះអាសន្នតាមច្រកទ្វារចូលរបស់ អ.វ.ត.ក.។
- ភ្ញៀវទាំងអស់នឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យខាងសន្តិសុខស្របតាមនីតិវិធីរបស់អង្គភាពសន្តិសុខនិងសុវត្ថិភាព។



ECCC * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

A421/I

- ទិន្នន័យកត់ត្រាការចេញចូល នឹងត្រូវបានចុះក្នុងបញ្ជីកត់ត្រាការចូលសួរសុខទុក្ខរបស់មន្ទីរឃុំឃាំងដែលចុះនាមនិងគោត្តនាម កាលបរិច្ឆេទ ពេលចូល/ចេញ និងថ្ងៃផុតកំណត់នៃអត្តសញ្ញាណប័ណ្ណ។
- ភ្ញៀវនឹងត្រូវបានតម្រូវឲ្យទុកអត្តសញ្ញាណប័ណ្ណរបស់ខ្លួននៅប៉ុស្តិ៍សន្តិសុខច្រកចូល ហើយរក្សាទុកសំរាប់ប្រគល់ជូនសាម៉ីជនវិញនៅពេលចេញពីបរិវេណ អ.វ.ត.ក.។
- អ្នកយាមមន្ទីរឃុំឃាំងត្រូវជូនដំណឹងប្រធានមន្ទីរឃុំឃាំងអំពីការមកដល់របស់ភ្ញៀវ។
- នៅចុងបញ្ចប់នៃការសួរសុខទុក្ខ មន្ទីរឃុំឃាំងត្រូវជូនដំណឹងមកសន្តិសុខ អ.វ.ត.ក. ដើម្បីមន្ត្រីទៅកាន់ក្លោងទ្វារមន្ទីរឃុំឃាំងដើម្បីអមដំណើរការពារភ្ញៀវត្រឡប់ទៅកាន់ច្រកភ្ញៀវចេញចូលវិញ។
- ការអមដំណើរនិងការទទួលខុសត្រូវ នឹងត្រូវបានបញ្ចប់នៅពេលដែលភ្ញៀវបានចាកចេញផុតពីបរិវេណ អ.វ.ត.ក.។
- ឯកសារនិងវត្ថុទាំងអស់ដែលត្រូវបានប្រមូលពីភ្ញៀវក្នុងពេលត្រួតពិនិត្យ នឹងត្រូវប្រគល់ជូនវិញ នៅពេលភ្ញៀចេញពីបរិវេណ អ.វ.ត.ក.។
- គ្មានករណីណាមួយអាចអនុញ្ញាតឲ្យភ្ញៀវចេញចូលមន្ទីរឃុំឃាំងដោយគ្មានការអមដំណើរការពារឡើយ។



ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh